00637174

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

D427/4/15

**តាមនាមប្រជាពលរដ្ឋកម្ពុជា និងអង្គការសហប្រជាជាតិ និងដោយអនុវត្តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីចោទប្រកាន់ឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តនៅក្នុងសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស.(អបជ ១០៤)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 01 / 2011
ម៉ោង (Time/Heure): 10:03
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ចំពោះមុខ:
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១

---

**សាធារណៈ:**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ**

---

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew T. CAYLEY

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Siegfried BLUNK

**ជនជាប់ចោទ**
ខៀវ សំផន

**សហមេធាវីការពារក្តី**
ស សូវ៉ាន
Jacques VERGÈS

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00637175

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ១០៤)

លេខ/No. D427/4/15

**មេធាវីនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី**

ឡោ ជុនធី
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
ពេជ អង្គ
ជេត វណ្ណលី
វ៉ែន ពៅ
ទី ស្រីនណា
សំ សុគង់
Martine JACQUIN
Philippe CANONNE

Elizabeth RABESANRATANA
Mahdev MOHAN
Olivier BAHOUGNE
Silke STUDZINSKY
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Marie GUIRAUD
Lyma Thuy NGUYEN
Laure DESFORGES
Isabelle DURAND
Françoise GAUTRY
Christina MARTINEAU
Pascal AUBOIN
Ferdinand Djammen-Nzepa
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គបុរេជំនុំជម្រះ” និង “អ.វ.ត.ក.”) បានទទួលនូវ “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ” ដែលបានដាក់ដោយ ខៀវ សំផន កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ (“បណ្តឹងឧទ្ធរណ៍” និង “ម្ចាស់បណ្តឹងឧទ្ធរណ៍”) ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជម្រះចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ចេញដោយសហចៅក្រមស៊ើបអង្កេត[1]។

១. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានប្រកាសសេចក្តីសម្រេចជាស្ថាពរលើបណ្តឹងឧទ្ធរណ៍នេះ និងបានប្រកាសឲ្យបានដឹងជាមុនថា សេចក្តីសម្រេចដែលមានសំអាងហេតុចំពោះបណ្តឹងឧទ្ធរណ៍នេះ នឹងចេញទៅតាមពេលវេលាសមស្រប។

២. ជាពិសេស **អង្គបុរេជំនុំជម្រះ**បានសម្រេចជាឯកច្ឆ័ន្ទថា៖

១. បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន។

២. ជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានបង្គាប់ឲ្យបញ្ជូនខ្លួន ទៅជំនុំជម្រះ ដូចដែលបានចែង នៅក្នុងដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដែលត្រូវយកមកពិចារណារួមជាមួយនឹងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ[2] ព្រមទាំងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[3] ដែលអង្គបុរេជំនុំជម្រះប្រកាសនៅក្នុងថ្ងៃនេះ ចំពោះជនជាប់ចោទទាំងអស់នៅក្នុងរឿងនេះ ដោយដីកាដំណោះស្រាយត្រូវបានកែប្រែដូចខាងក្រោមនេះ៖

១. បន្ថែម “អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធ” ដែលជាលក្ខខណ្ឌតម្រូវ “ធាតុផ្សំ”មួយ នៅក្នុងផ្នែកទីIV(ក)នៃជំពូក៣ នៃដីកាដំណោះស្រាយ។

[1] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ បានដាក់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”)។

[2] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែ មករា ឆ្នាំ២០១១ (អបជ ១៤៥ និង១៤៦)

[3] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារីប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែ មករា ឆ្នាំ២០១១ (អបជ ៧៥)។

២.ឆ្លុតចោលបទរំលោភលើផ្លូវភេទចេញពីក្នុងកថាខណ្ឌ១៦១៣(ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កថាខណ្ឌ (ឆ))នៃដីកាដំណោះស្រាយ និងតម្កល់ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"។

៣. បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំខ្លួនមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៣. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះផ្តល់នូវសំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួន។

## សំអាងហេតុនៃសាលដីកា:

## I. ការរំលឹកពីនីតិវិធី និងបទបញ្ញាត្តិស្តីពីបណ្តឹងឧទ្ធរណ៍

៤. បណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើក្នុងក្របខណ្ឌនៃកិច្ចស៊ើបសួរប្រឆាំងទៅនឹង នួន ជា អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន ដែលត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ អំពើប្រល័យពូជសាសន៍ អំពើមនុស្សឃាត អំពើទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងសាសនា បទល្មើសដែលបានចែង ក្នុងមាត្រា ៣ មាត្រា ៤ មាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("ច្បាប់ស្តីពី អ.វ.ត.ក.") និងមាត្រា២០៩ មាត្រា២១០ មាត្រា៥០០ មាត្រា៥០១ មាត្រា៥០៣ ដល់៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ រឹតតែច្បាស់លាស់ជាងនេះទៅទៀត បណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើប្រឆាំងទៅនឹងដីកាបញ្ជូនរឿងទៅជម្រះចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ចេញដោយសហចៅក្រមស៊ើបអង្កេត ក្រោយពីបញ្ចប់កិច្ចស៊ើបសួរ ខាងលើ។

៥.ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើសុំអង្គជំនុំជម្រះឱ្យធ្វើការកត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជម្រះ ត្រូវបានចេញដោយរំលោភលើវិធាននៃកិច្ចស៊ើបសួរ ហើយបានបញ្ចប់មុនកាលកំណត់នូវកិច្ចស៊ើបសួរដែលមាន

លក្ខណៈមិនពេញលេញ និងធ្វើឡើងសម្រាប់តែដាក់បន្ទុកប៉ុណ្ណោះ[៤]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងក្នុងលក្ខណៈទូទៅថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានធ្វើឡើងដោយឆ្លងកាត់សវនាការតទល់គ្នាណាមួយឡើយ ដែលដីកានេះមិនបានគិតទៅដល់វិសាលភាពនៃទំនាក់ទំនងជាយថាហេតុរវាងគាត់ជាមួយនឹងអង្គហេតុដែលបានចោទប្រកាន់ ហើយដែលដីកានេះ ពុំបានអនុញ្ញាតិឱ្យមានការបង្ហាញនូវការពិត និងការស៊ើបសួរផ្សេងៗទៀតត្រូវតែធ្វើឡើងដោយខានមិនបាន ដើម្បីធានាឱ្យមានការជំនុំជម្រះសេចក្ដីមួយប្រកបដោយគុណភាព[៥]។

៦.ម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងនូវអំណះអំណាងក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ចំនួនពីរ។ អំណះអំណាងទីមួយលើកឡើងអំពីអវត្តមាននៃសវនាការតទល់មុខគ្នា[៦] ដោយសារ(១) ការបដិសេធសិទ្ធិឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា[៧] (២) អវត្តមាននៃភស្តុតាងជាភាសាបារាំង និងភាសាខ្មែរ[៨] និង (៣) ភាពពុំច្បាស់លាស់នៃកិច្ចដំណើរការរបស់សហចៅក្រមស៊ើបអង្កេត។ អំណះអំណាងក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ទីពីរបានលើកឡើងថា កិច្ចស៊ើបសួរមានលក្ខណៈមិនពេញលេញ លម្អៀង និង*បង្កគ្រោះថ្នាក់*។

៧.ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើសុំឱ្យមានការបើកសវនាការមួយ ដែលខ្លួនគិតថា មានលក្ខណៈត្រឹមត្រូវហើយយល់ឃើញថា សវនាការត្រូវធ្វើឡើងជាសាធារណៈ ដើម្បីជាប្រយោជន៍យុត្តិធម៌[៩]។

៨.ជាកិច្ចឆ្លើយតប សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ពុំមានហេតុផលសមស្របណាមួយ ដែលតម្រូវឱ្យមានការរៀបចំសវនាការដូចខាងលើនេះឡើយ[១០]។ សហព្រះរាជអាជ្ញាបានស្នើសុំទៅអង្គបុរេជំនុំជម្រះ ឱ្យ

[៤] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១។

[៥] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ២។

[៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៦២-៨៤។

[៧] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៦៣-៦៨។

[៨] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៦៩-៧៣។

[៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៥៨-៦០ សំដៅជាពិសេសដល់វិធាន៧៧(៦) នៃវិធានផ្ទៃក្នុង។

[១០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/4/7 "ចម្លើយតបរបស់សហព្រះរាជអាជ្ញា" កថាខណ្ឌ២៧។

ធ្វើការបដិសេធចោលបណ្តឹងឧទ្ធរណ៍ ដោយហេតុថា បណ្តឹងនេះមិនអាចទទួលយកបាន ដោយមូលហេតុនីតិវិធី និងពុំមានមូលដ្ឋានច្បាប់សមស្រប[១១]។ សហព្រះរាជអាជ្ញាក៏បានស្នើសុំផងដែរទៅអង្គបុរេជំនុំជម្រះឱ្យធ្វើការបញ្ជូនដីកាបញ្ជូនរឿងទៅជម្រះ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយបន្តឃុំខ្លួនម្ចាស់បណ្តឹងឧទ្ធរណ៍នេះបណ្តោះអាសន្ន រហូតដល់ចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[១២]។

៩.ក្រុម"មេធាវីគ្មានព្រំដែនបារាំង"[១៣] ក៏ដូចជាសហមេធាវីនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយមេធាវី ជេត វណ្ណលី មេធាវី ទី ស្រ៊ីនណា និងមេធាវី វ៉ែន ពៅ[១៤] បានធ្វើសេចក្តីសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍មានលក្ខណៈមិនអាចទទួលយកបាន ដោយហេតុថា អំណះអំណាងក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ពុំស្ថិតនៅក្នុងដែនអនុវត្តនៃវិធាន៧៤(៣) នៃវិធានផ្ទៃក្នុង ហើយក្រុមមេធាវីទាំងនោះក៏បានស្នើសុំជាលក្ខណៈបន្ទាប់បន្សំឱ្យតម្កល់ដីកាបញ្ជូនរឿងទៅជម្រះ។

១០. អង្គបុរេជំនុំជម្រះយល់ឃើញថា មិនចាំបាច់រៀបចំសវនាការបែបនេះនោះទេ ដោយសារតែចំណុចវិវាទអាចត្រូវបានដោះស្រាយ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរលម្អិតរបស់ភាគីនានា។

## II. អំពីភាពដែលអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១១.ម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាងថា បណ្តឹងឧទ្ធរណ៍របស់ខ្លួនមានលក្ខណៈអាចទទួលយកបាន យោងតាមវិធាន៧៤(៣)(ក)នៃវិធានផ្ទៃក្នុង ("វិធាន") ដោយហេតុថា ដីកាបញ្ជូនរឿងទៅជម្រះ ទទួលស្គាល់យុត្តាធិការរបស់ អ.វ.ត.ក. និងដោយយោងតាមវិធាន២១(១) ពីព្រោះដីកាបញ្ជូនរឿងទៅជម្រះត្រូវបាន

---

[១១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣១។

[១២] ដូចខាងខាងលើ។

[១៣] សារណារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី "ក្រុមមេធាវីគ្មានព្រំដែនប្រទេសបារាំង" តបនឹងបណ្តឹងឧទ្ធរណ៍ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/4/8។

[១៤] សេចក្តីអង្កេតរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍អ្នកស្រី ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/4/10។



PRE-TRIAL CHAMBER E.C.C.C * C.E.T.C CHAMBRE PRÉLIMINAIRE

ចេញដោយរំលោភលើវិធាននៃកិច្ចស៊ើបសួរ ដែលធានានូវសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌[១៥]។

១២. សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍មានលក្ខណៈមិនអាចទទួលយកបាន ដោយហេតុថា បណ្តឹងនេះពុំបានលើកឡើងនូវបញ្ហាណាមួយ ដែលពាក់ព័ន្ធនឹងយុត្តាធិការ។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានបន្ថែមទៀតថា អង្គបុរេជំនុំជម្រះពុំអាចពង្រីកដែនយុត្តាធិការរបស់ខ្លួន ដូចដែលបានកំណត់ដោយវិធាន៧៤ នៃវិធានផ្ទៃក្នុងដែលថា មានតែដីការបស់សហចៅក្រមស៊ើបអង្កេតដែល "បញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក."មួយគត់ ដែលអាចប្តឹងឧទ្ធរណ៍បាន[១៦]។ ចំពោះសញ្ញាណនៃយុត្តាធិការ ដែលពុំត្រូវបានកំណត់និយមន័យដោយវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការសម្រេចដោយអនុលោមតាមវិធាន៧២(ឃ) នៃវិធាននីតិវិធី និង វិធានភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលវិធាននេះបានកំណត់និយមន័យយ៉ាងច្បាស់អំពីអ្វីដែលគេហៅថា "ការជំទាស់យុត្តាធិការ" ពោលគឺការជំទាស់ដែលថា ការចោទប្រកាន់មិនមានជាប់ពាក់ព័ន្ធទៅនឹងយុត្តាធិការបុគ្គល យុត្តាធិការដែនដី ឬយុត្តាធិការពេលវេលារបស់តុលាការ ឬមិនជាប់ពាក់ព័ន្ធទៅនឹងការរំលោភបំពានណាមួយ ក្នុងចំណោមការរំលោភបំពាននានាដូច ដែលបានកំណត់នៅក្នុងលក្ខន្តិកៈនៃតុលាការ[១៧]។ ដូច្នេះ យោងតាមសហព្រះរាជអាជ្ញា ការអះអាងដែលលើកឡើងអំពីវិការៈនៃទម្រង់នៅក្នុងដីកាចោទប្រកាន់ ឬ កំហុសនីតិវិធីនៅក្នុងការបំពេញកិច្ចស៊ើបសួរ មិនស្ថិតនៅក្នុងប្រភេទបញ្ហា ដែលពាក់ព័ន្ធនឹងយុត្តាធិការឡើយ[១៨]។ ម្យ៉ាងទៀត ផ្អែកលើការអះអាងរបស់សហព្រះរាជអាជ្ញាការពឹងផ្អែកលើវិធាន២១នៃវិធានផ្ទៃក្នុង មិនអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍ឡើយ[១៩]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា បញ្ហាដែលបានលើកឡើងនៅក្នុងអំណះអំណាង នៃការធ្វើបណ្តឹងឧទ្ធរណ៍មួយចំនួន ត្រូវបានសម្រេចសេចក្តីក្នុង លក្ខណៈជាអាជ្ញាអស់ជំនុំ រួចរាល់ហើយ[២០]។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

---

[១៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥០។

[១៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥។

[១៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៧។

[១៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៧ ដល់១៧។

[១៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៨ ដល់១៩។

[២០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២០ ដល់២៦។ សហព្រះរាជអាជ្ញាយល់ឃើញថា សិទ្ធិរបស់ដើមបណ្តឹងពាក់ព័ន្ធនឹងការបកប្រែ លទ្ធភាពក្នុងការស្តាប់ចម្លើយអតីតអ្នកទទួលខុសត្រូវនៃរដ្ឋាភិបាលសហរដ្ឋអាមេរិក ការដាក់បញ្ចូលទៅក្នុង

១៣.ផ្អែកលើមូលដ្ឋានទីមួយនៃភាពដែលអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានបង្ហាញថា ទោះបីជាសិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជម្រះ មិនត្រូវបានចែងដោយវិធានផ្ទៃក្នុងក៏ដោយ ក៏វិធាន៧៤(៣)(ក) ដូចបានបញ្ជាក់ខាងលើ ចែងថា ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក.[២១]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានអះអាងថា ដីកាដំណោះស្រាយគឺជាដីកាបញ្ជូនរឿងទៅជម្រះ ហើយថា សហចៅក្រមស៊ើបអង្កេតបានកំណត់និយមន័យនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដែលអនុវត្តទៅលើករណីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍នេះ ដែលបញ្ជាក់ផងដែរអំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក. ដើម្បីវិនិច្ឆ័យទោសគាត់។ ដោយឡែក ម្ចាស់បណ្ដឹងឧទ្ធរណ៍យល់ឃើញថា ចាប់ពីពេលនេះទៅ គាត់មានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជម្រះ "លើគ្រប់ផ្នែកទាំងអស់"[២២]។ ក្រោយពីបានអានទឡ្ហីករណ៍នានា នៃបណ្ដឹងឧទ្ធរណ៍ឱ្យអស់សេចក្ដី ដែលជាទូទៅ[២៣] មិនពាក់ព័ន្ធជាមួយនឹងខ្លឹមសារផ្ទាល់នៃដីកាបញ្ជូនរឿងទៅជម្រះ ហើយមិនបានលើកឡើងអំពីករណីកំហុសអង្គច្បាប់ ឬ អង្គហេតុ ដែលបានប្រព្រឹត្តដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាបញ្ជូនរឿងទៅជម្រះរបស់ខ្លួនឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្រៅអំពីសិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជម្រះ"លើគ្រប់ផ្នែកទាំងអស់" ម្ចាស់បណ្ដឹងឧទ្ធរណ៍សន្និដ្ឋានថា ចាប់ពីពេលដែលសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អំពីយុត្តាធិការនៃ អ.វ.ត.ក. ដើម្បីវិនិច្ឆ័យទោសលើម្ចាស់បណ្ដឹងឧទ្ធរណ៍ ម្ចាស់បណ្ដឹងឧទ្ធរណ៍អាចដាក់នូវសារណាបណ្ដឹងឧទ្ធរណ៍ទៅនឹងភាពខ្វះខាតនៃ

---

សំណុំរឿងនូវឯកសារដែលផ្ទុកព័ត៌មានទាក់ទងនឹងមុខងារ ដែលត្រូវបានបំពេញយ៉ាងពិតប្រាកដ ដោយដើមបណ្ដឹងឧទ្ធរណ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ការប្រើប្រាស់ព័ត៌មានដែលអាចបានមកពីការធ្វើទារុណកម្ម ក៏ដូចជាភាពអនាគតិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺសុទ្ធសឹងតែជាបញ្ហាដែលត្រូវបានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសម្រេចដោយអង្គបុរេជំនុំជម្រះ ហេតុដូច្នេះ បញ្ហាទាំងនេះមិនអាចត្រូវបានលើកយកមកកតវ៉ាតទៅទៀតបានឡើយ។

[២១] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៥១។

[២២] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៥២។

[២៣] ផ្នែកទីបីនៃអំណះអំណាងបណ្ដឹងឧទ្ធរណ៍ទីពីរ អះអាងពីលក្ខណៈគ្រោះថ្នាក់នៃកិច្ចស៊ើបសួរ និងបរិហារអំពី (១) អវត្តមាននៅក្នុងដីកាដំណោះស្រាយ ទោះបីជាមានការសន្យាពីសំណាក់សហចៅក្រមស៊ើបអង្កេតលើចំណុចនេះក៏ដោយ នូវចម្លើយតបទៅនឹងពាក្យសុំបំពេញកិច្ចស៊ើបសួរ និងការបំភ្លឺដែលដាក់ដោយមេធាវីការពារក្ដីពាក់ព័ន្ធនឹងការប្រើប្រាស់ ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម (បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១១០-១១២) និង (២) ការយោងដោយសហចៅក្រមស៊ើបអង្កេតទៅលើចម្លើយសារភាពដែលបានមកដោយសារការធ្វើទារុណកម្ម ដើម្បីសន្និដ្ឋាននៅកថាខណ្ឌ១១៨៤ នៃដីកាដំណោះស្រាយថា ខៀវ សំផន "បានចូលរួមក្នុងការចាប់ខ្លួន វន វេត នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ទៅមន្ទីរគណៈអចិន្ត្រៃយ៍"។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C * C.E.T.C * PRÉLIMINAIRE

កិច្ចស៊ើបសួរ។ អំណះអំណាងនៃបណ្តឹងឧទ្ធរណ៍ទាំងពីរ និងទឡ្ហីករណ៍ទាំងអស់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលធ្វើជាមូលដ្ឋាននៃអំណះអំណាងបណ្តឹងឧទ្ធរណ៍ទាំងនោះ ត្រូវប្រកាន់យកនូវគោលការណ៍ដូចគ្នា លើកលែងទឡ្ហីករណ៍ទាំងឡាយដែលបញ្ជាក់ខាងក្រោមបំផុតនេះ[២៤]។

១៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ផ្អែកលើវិធាន៧៤នៃវិធានផ្ទៃក្នុង មិនមែនគ្រប់ដីកាទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេត អាចត្រូវបានប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយភាគីណាមួយឡើយ។ ជាក់ស្តែង នៅខណៈដែលសហព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅនឹងរាល់ដីកាទាំងឡាយដែលចេញដោយសហចៅក្រមស៊ើបអង្កេត ស្របតាមវិធាន៧៤(២)នៃវិធានផ្ទៃក្នុង ដីកានិងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលជនត្រូវចោទ ឬ ជនជាប់ចោទអាចប្តឹងឧទ្ធរណ៍បាន ត្រូវបានកំណត់ដោយវិធាន៧៤(៣)។ ដីកាបញ្ជូនរឿងទៅជម្រះ មិនត្រូវបានរាប់បញ្ចូល ដោយវិធាននេះឡើយ។ ដោយឡែក អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា វិធាន៧៤ (៣) នៃវិធានផ្ទៃក្នុង ចែងថា៖

> ជនត្រូវចោទ ឬជនជាប់ចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម៖
>
> ក). ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

អាស្រ័យហេតុនេះ ទោះបីជាដីកាបញ្ជូនរឿងទៅជម្រះមិនអាចត្រូវបានប្តឹងឧទ្ធរណ៍ដោយជនជាប់ចោទក៏ដោយ ក៏អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីអោយដីកាណាមួយបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក. ដីកានោះត្រូវតែអាចប្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងបញ្ហាស្តីពីយុត្តាធិការ ដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត[២៥]។ សំណួរដែលចោទឡើង ចាប់ពីពេលនេះទៅ ចំពោះអង្គបុរេជំនុំជម្រះ គឺត្រូវដឹងថា តើចាប់តាំងពីពេល ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះបញ្ជាក់ជាទូទៅ អំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ដើម្បីវិនិច្ឆ័យទោសខ្លួន ដើមបណ្តឹងឧទ្ធរណ៍មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា"លើគ្រប់ផ្នែកទាំងអស់" ដូចដែលដើមបណ្តឹងឧទ្ធរណ៍លើកឡើងដែរឬទេ។ ករណីនេះបានចាត់បញ្ចូលដីកាបញ្ជូនរឿងទៅជម្រះ ទៅក្នុងបញ្ជីនៃដីកា និងសេចក្តីសម្រេច របស់សហចៅក្រមស៊ើបអង្កេត

[២៤] ដូចខាងលើ។

[២៥] ក្នុងន័យនេះ សូមមើលសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D345/5/11។



PRE-TRIAL CHAMBER CHAMBRE PRELIMIN E.C.C.C. C.E.T.C.

ដែលរៀបរាប់ដោយវិធានផ្ទៃក្នុងថាអាចប្តឹងឧទ្ធរណ៍បាន។ ជាក់ស្តែង ការបកស្រាយនេះពុំស្របគ្នាទៅនឹងវិធីសាស្ត្រ ដែលកំណត់ដោយវិធានផ្ទៃក្នុងទៅលើចំណុចនេះនោះទេ។ ជាក់ស្តែង វិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ពុំបានអនុញ្ញាតឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងភាពខ្វះខាតនៃនីតិវិធីស៊ើបសួរឡើយ។

១៥. ជាចុងក្រោយ អង្គហេតុដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ដែលថា ផ្អែកលើច្បាប់របស់បារាំង ក្នុងករណីបទឧក្រិដ្ឋ ជនជាប់ចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាបញ្ជូនរឿងទៅជម្រះបាន ហើយលទ្ធភាពនេះ ត្រូវបានបង្កើតឡើងដោយច្បាប់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០ សម្តៅពង្រឹងកិច្ចការពារគោលការណ៍សច្ចាធារណ៍នៃនិរទោស[២៦] មិនអាចធ្វើជាមូលហេតុសមស្រប សម្រាប់ឱ្យមានការប្រព្រឹត្តផ្ទុយទៅនឹងការកំណត់ជាក់ច្បាស់អំពីករណីនៃបណ្តឹងឧទ្ធរណ៍ដូចដែលបានលើកឡើងដោយវិធាន ៧៤ (៣) (ក) នៃវិធានផ្ទៃក្នុងឡើយ។

១៦. អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានឡើយ ដោយផ្អែកលើមូលដ្ឋាននៃវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ ពេលនេះ អង្គបុរេជំនុំជម្រះបែរទៅរកអំណះអំណាងទី២ លើភាពអាចទទួលយកបាននៃបណ្តឹងដែលលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍។

១៧. ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះមេត្តាពិចារណា ដោយផ្អែកលើបទបញ្ញត្តនៃវិធាន២១.១ នៃវិធានផ្ទៃក្នុង ថាតើមានការបកស្រាយឱ្យបានទូលំទូលាយដែរ ឬទេ ពីសិទ្ធិរបស់ជនត្រូវចោទពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ដើម្បីធានាឱ្យបានថា នីតិវិធីនៅដំណាក់កាលស៊ើបអង្កេតប្រព្រឹត្តទៅដោយយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ ព្រមទាំងដើម្បីរក្សាឱ្យបាននូវតុល្យភាពនៃសិទ្ធិរបស់ភាគី[២៧] នោះ។ ដើមបណ្តឹងអះអាងថា គាត់ស្ថិតនៅក្នុងករណីនេះ ដោយហេតុថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានធ្វើឡើងដោយរំលោភយ៉ាងជាក់ច្បាស់ទៅលើវិធានស៊ើបសួរ ជាពិសេស វិធានពាក់ព័ន្ធនឹងភាពចាំបាច់

---

[២៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥២។

[២៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥៣ យោងទៅលើ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ" ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ A190/I/20 ("សាលដីកាទាក់ទងនឹងការបកប្រែ") កថាខណ្ឌ៣៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ក្នុងការទទួលបានចម្លើយទៅនឹងដីកាសន្និដ្ឋានស្ថាពរពីដើមបណ្តឹង ក៏ដូចជាភាពចាំបាច់ក្នុងការផ្តល់ឯកសារព័ត៌មាននានាដល់ដើមបណ្តឹងសម្រាប់ត្រៀមរៀបចំការពារខ្លួនគាត់ [២៨]។

១៨. វិធាន២១នៃវិធានផ្ទៃក្នុងដែលចែងពីគោលការណ៍ជាសារវ័ន្ត បញ្ញត្តជាអាទិ៍ថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ (...) ជនជាប់ចោទ និង (...) ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"[២៩] ហើយវិធាននេះចែងទាក់ទងនឹងបញ្ហានេះថា "ដំណើរការនីតិវិធីនៅក្នុង អ.វ.ត.ក. ត្រូវតែមានយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ"[៣០] ហើយ "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ [...] មានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន"[៣១]។ អង្គបុរេជំនុំជម្រះស្នើសុំឱ្យពិចារណាថា អង្គហេតុ និង កាលៈទេសៈនានានៃបណ្តឹងឧទ្ធរណ៍ បានតម្រូវឱ្យមានការបកស្រាយមួយ ទូលំទូលាយអំពីសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដើម្បីធានាដល់យុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនោះ។

១៩. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ផ្នែកនៃបណ្តឹងឧទ្ធរណ៍ ដែលប្រើសម្រាប់អះអាងពីភាពអាចទទួលយកបាននៃបណ្តឹងរបស់ខ្លួន លើកឡើងតែអង្គហេតុដែលថា គាត់មិនយល់ស្របជាមួយនឹងដីកាសន្និដ្ឋានស្ថាពរ ដោយមិនមានពន្យល់ថា តើត្រង់ចំណុចណាដែលថា អង្គហេតុនោះតម្រូវឱ្យមានការបកស្រាយឱ្យបានទូលំទូលាយ ពីសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជម្រះនោះទេ[៣២]។ ទន្ទឹមនឹងនេះដែរ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលផលប៉ះពាល់នៃអំណះអំណាងទាំងពីរ ដែលបានលើកឡើងទាំងស្រុងដោយដើមបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងចំណុចនេះ ដែលគាត់គិតថា មានភាពសមហេតុផល សម្រាប់ឱ្យបណ្តឹងឧទ្ធរណ៍របស់គាត់អាចទទួលយកបាននោះ។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានផ្អែក ជាពិសេស ទៅលើ

---

[២៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥៤។

[២៩] វិធាន ២១(១)។

[៣០] វិធាន ២១(១)(ក)។

[៣១] វិធាន ២១ (១)(ឃ)។

[៣២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥៤។



PRE-TRIAL CHAMBER CHAMBRE ... C.C.C. C.E.T.C.

សេចក្តីសម្រេចដែលពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍ស្តីពីការបដិសេធចម្លើយតប របស់ អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ[៣៣]។ អង្គបុរេជំនុំជម្រះបានរំលឹកថា ដូចគ្នាទៅនឹងមាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាដែរ ("ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា") វិធានផ្ទៃក្នុង ពុំបានប្រគល់យ៉ាងជាក់ច្បាស់ ដល់ជនត្រូវចោទ នូវសិទ្ធិក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាឡើយ[៣៤]។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការបដិសេធចម្លើយតបរបស់ អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ អង្គបុរេជំនុំជម្រះបានលើកឡើងថា ប្រព័ន្ធច្បាប់បារាំង ដែលជាប្រពៃណីផ្តល់សិទ្ធិខ្លាំងដល់ចៅក្រមក្នុងដំណើរការនីតិវិធី ដែលក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានយកលំនាំតាម ត្រូវបានកែប្រែចាប់តាំងពីឆ្នាំ២០០៧មក ដើម្បីធានាឲ្យរឹតតែមានតុល្យភាពរវាងសិទ្ធិរបស់ភាគីក្នុងដំណាក់កាលស៊ើបសួរ។ ម្យ៉ាងទៀត អង្គបុរេជំនុំជម្រះបានពិចារណាថា បើទោះបីជាពុំមានការទទួលស្គាល់ជាក់លាក់ នូវសិទ្ធិរបស់ជនត្រូវចោទក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាក៏ដោយ នៅខណៈដែលសហចៅក្រមស៊ើបអង្កេតត្រូវបង្គាប់ឲ្យអនុវត្តតាមដោយវិធាន២១ (១) (ក) និង(ខ)នៃវិធានផ្ទៃក្នុង ដូចបានបញ្ជាក់ខាងលើក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតពុំបានប្រព្រឹត្តនូវកំហុសឆ្គងទេ ក្នុងការដែលបានទទួលយកចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ដែលសម្រេចចោទប្រកាន់ទៅលើ ឈ្មោះ កាំង ហ្គេកអ៊ាវ ក្នុងសំណុំរឿង ០០១ នោះ[៣៥]។ ជាងនេះទៅទៀត អង្គបុរេជំនុំជម្រះបានវាយតម្លៃថា ការណ៍ដែលខ្លួនបង្គាប់ឲ្យក្រឡាបញ្ជីធ្វើការបដិសេធចម្លើយតបរបស់ អៀង សារី ទៅ នឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតពុំបានគោរព

---

[៣៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥៤ និង ៦៣-៦៥ យោងពិសេសទៅលើ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និង សំណើសុំផ្អាកដំណើរការនីតិវិធី ឯកសារ D390/1/2/4 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ") កថាខណ្ឌ២៣។

[៣៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅ នឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ១៦។

[៣៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅ នឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ១៦-១៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ដល់សិទ្ធិរបស់ភាគីជនត្រូវចោទ ក្នុងការទទួលបាននូវសមភាពនៃកម្លាំង បើធៀបជាមួយសហព្រះរាជអាជ្ញា ក៏ដូចជា ពុំបានគោរពដល់គោលការណ៍សមភាពនៃការប្រព្រឹត្តចំពោះមុខច្បាប់ផងដែរ[៣៦]។

២០.គួរកត់សម្គាល់ថា ទាក់ទងនឹងបញ្ហានេះ ស្ថានភាពរបស់ដើមបណ្តឹងមានភាពខុសប្លែកគ្នាពីស្ថានភាពរបស់ អៀង សារី ជាជនជាប់ចោទដូចរូបគាត់ដែរ ព្រោះថា សហមេធាវីរបស់គាត់មិនបានបង្ហាញនូវភាពខ្វះខ្នែងដូចសហមេធាវីរបស់ អៀង សារី ទេ។ ដោយមិនមានវិធានណាមួយអនុញ្ញាតឱ្យគាត់ធ្វើការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ហើយចាប់តាំងពីពេល ដែលសហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពរ សហមេធាវីរបស់ អៀង សារី បានបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការដាក់នូវចម្លើយតបមួយព្រមទាំងដាក់សំណើបន្ទាន់មួយ ដល់សហចៅក្រមស៊ើបអង្កេតស្នើសុំដាក់ចម្លើយមួយមានទំព័រច្រើនជាងចំនួនទំព័រដែលអនុញ្ញាត និងស្នើសុំពន្យារពេលដាក់ចម្លើយតបនេះ។ បន្ទាប់មក នៅចំពោះមុខការបដិសេធចោលសំណើសុំនេះពីសំណាក់សហចៅក្រមស៊ើបអង្កេត ដោយមូលហេតុថា ពុំមានបទបញ្ញត្តិណាមួយ នៃវិធានផ្ទៃក្នុង ដែលបានចែងអំពីការធ្វើចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរទេនោះ[៣៧] សហមេធាវីបានត្រៀមរៀបចំចម្លើយតបរបស់ខ្លួន ដោយព្យាយាមធ្វើយ៉ាងណាមិនឱ្យមានការយឺតយ៉ាវដល់កិច្ចដំណើរការនីតិវិធីឡើយ[៣៨] និងព្យាយាមដាក់ចម្លើយតបនេះ ដោយសម្អាងទៅលើការទទួលយកពីពេលមុនរបស់សហចៅក្រមស៊ើបអង្កេត នូវចម្លើយតបរបស់ជនត្រូវចោទក្នុងសំណុំរឿង០០១[៣៩]។ ជាចុងក្រោយ សហមេធាវី របស់ អៀង សារី បានធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសេចក្តីណែនាំរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបង្គាប់ឱ្យធ្វើការបដិសេធចោលនូវការ ដាក់ចម្លើយតបខាងលើ[៤០]។

---

[៣៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ២៣។

[៣៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ៣។

[៣៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ២២។

[៣៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ៤។

[៤០] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

២១. ផ្ទុយទៅវិញ សហមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានផ្តួចផ្តើមគំនិតណាមួយ មុនពេលការចេញដីកាបញ្ជូនរឿងទៅជម្រះ ដើម្បីការពារសិទ្ធិរបស់ពួកគេឡើយ។ ផលវិបាកនៃភាពអសកម្មនេះ ត្រូវតែបានវាយតម្លៃ ដោយផ្អែកទៅលើបរិបទដែលភាពអសកម្មនោះ រួមមានដំណើរជិតចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលសហមេធាវីមិនអាចមិនដឹងមិនលឺនោះទេ។ ការណ៍ដែលថា វិធានផ្ទៃក្នុងពុំបានចែងអំពីសិទ្ធិធ្វើការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ហើយដីកាដែលពាក់ព័ន្ធនឹងការបកប្រែឯកសារ ដែលបានទទួលស្គាល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានសំណៅបកប្រែដីកាសន្និដ្ឋានស្ថាពរ ពុំបានកំណត់អំពីរយៈពេលទាក់ទងនឹងការដាក់ចម្លើយតបទេ[៤១]។ សហមេធាវីពុំបានបង្ហាញដល់សហចៅក្រមស៊ើបអង្កេត នូវចេតនារបស់ខ្លួនក្នុងការដាក់នូវចម្លើយតបឡើយ។ សហមេធាវីពុំបានប្រើប្រាស់នូវសិទ្ធិរបស់ពួកគេ ក្នុងការទទួលបាននូវសំណៅបកប្រែជាភាសាបារាំងនៃដីកាសន្និដ្ឋានស្ថាពរ និងពុំបានធ្វើការស្នើសុំទៅសហចៅក្រមស៊ើបអង្កេត ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតផ្អាកការចេញដីកាបញ្ជូនរឿងទៅជម្រះ មុនពេលដែលសំណៅបកប្រែជាភាសាបារាំងនៃដីកាសន្និដ្ឋានស្ថាពរ ត្រូវបានដាក់ ហើយក៏ពុំបានស្នើសុំឱ្យមានការបញ្ជាក់ពីរយៈពេលសម្រាប់ឆ្លើយតបផងដែរ។ លើសពីនេះ សហមេធាវីក៏ពុំបានប្រើប្រាស់សមត្ថភាពខាងបកប្រែភាសារបស់ក្រុមខ្លួន ដើម្បីព្យាយាមធ្វើការឆ្លើយតប ដោយយោងទៅលើមូលដ្ឋាននៃសំណៅជាភាសាខ្មែរនៃដីកាសន្និដ្ឋានស្ថាពរ។ ផ្អែកលើកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ខណៈដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញរួចហើយ សហមេធាវីរបស់ដើមបណ្តឹងមិនមានសិទ្ធិលើកសំអាងពីការមិនគោរពសិទ្ធិរបស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ដើម្បីស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការបកស្រាយឱ្យបានទូលំទូលាយពីសិទ្ធិរបស់ខ្លួន ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ក្នុងរឿងនេះ ដើម្បីធានាបាននូវយុត្តិធម៌ក្នុងកិច្ចដំណើរការនីតិវិធីឡើយ។ ទោះបីជាសហមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានបង្ហាញអំពីភាពខ្នះខ្នែងរបស់ខ្លួនក៏ដោយ ប្រសិនណាជាអង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ អាចត្រូវបានគំរាមកំហែងក្នុងករណីមានការបដិសេធចោលបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះនឹងទទួលយកមកពិចារណាថា ការបដិសេធនេះ ត្រូវចាត់ទុកថាអាចទទួលយកបាន ដោយផ្អែកលើខ្លឹមសារនៃការបកស្រាយឱ្យបានទូលំទូលាយនូវវិធាន២១.១ នៃវិធានផ្ទៃក្នុង ព្រមទាំងធ្វើការពិនិត្យពិច័យឱ្យបានស៊ីជំរៅ។ វាពុំមែនជាករណីដូច្នោះឡើយ សម្រាប់ហេតុផលនានា

[៤១] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ("ដីកាសម្រេចពាក់ព័ន្ធនឹងការបកប្រែ") ផ្នែក ខ និង គ។

00637188



ដូចខាងក្រោម អង្គបុរេជំនុំជម្រះពុំបានយល់ឃើញថា បណ្ដឹងឧទ្ធរណ៍ខាងលើនេះ តម្រូវឱ្យមានការបកស្រាយណាមួយឡើយ។

២២. ជាបឋម អង្គបុរេជំនុំជម្រះសូមរំលឹកថា ពាក់ព័ន្ធនឹងករណីអញ្ញត្រកម្ម[៤២] បណ្ដឹងឧទ្ធរណ៍មិនទាក់ទងតាមបែបណាមួយទៅនឹងខ្លឹមសារ នៃដីកាបញ្ជូនរឿងទៅជម្រះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទាក់ទងនឹងអញ្ញត្រកម្មនេះ នៅក្នុងសេចក្ដីសម្រេចទាក់ទងនឹងភាពអាចទទួលយកបាន នៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្ដីអំពីការប្រើប្រាស់ឯកសារទទួលបាន ឬអាចទទួលបានតាមរយៈការធ្វើទារុណកម្ម អង្គបុរេជំនុំជម្រះអះអាងថាដំណើរការនីតិវិធីអនុវត្ត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងយុត្តិសាស្ត្ររបស់សាលាដំបូង ដែលលើកឡើងថា ឯកសារទទួលបានតាមរយៈទារុណកម្មមានភាពសមហេតុផល ក្នុងករណីដែលឯកសារនោះត្រូវបានធ្វើក្រោមអំពើទារុណកម្ម ហើយឯកសារទាំងនោះអាចបញ្ជាក់អង្គហេតុនេះ ប៉ុន្តែឯកសារទាំងនោះ "មិនបានដាក់បញ្ចូលក្នុងសំណុំរឿង ដើម្បីអះអាងពីភាពពិតនៃខ្លឹមសាររបស់វា"[៤៣] ដែលអនុញ្ញាតឱ្យធានាបានគ្រប់គ្រាន់នូវសិទ្ធិជនត្រូវចោទ ចែងដោយវិធាន ២១ នៃវិធានផ្ទៃក្នុង[៤៤]។ សន្មតថា ម្ចាស់បណ្ដឹងឧទ្ធរណ៍មានលទ្ធភាពឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ និងរំលឹកដល់សហចៅក្រមស៊ើបអង្កេតអំពីឯកសារយោងណាមួយ ដែលមិនស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយសារភាពនៅក្នុងឯកសារនេះ ម្ចាស់បណ្ដឹងឧទ្ធរណ៍អាចនឹងបញ្ចុះបញ្ចូលសហចៅក្រមស៊ើបអង្កេត ឱ្យដកឯកសារយោងបែបនេះ ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សិទ្ធិ

---

[៤២] ផ្នែកទីបីនៃអំណះអំណាងបណ្ដឹងឧទ្ធរណ៍ទីពីរ អះអាងពីលក្ខណៈគ្រោះថ្នាក់នៃកិច្ចស៊ើបសួរ និងបរិហារអំពី (១) អវត្តមាននៅក្នុងដីកាដំណោះស្រាយ ទោះបីជាមានការសន្យាពីសំណាក់សហចៅក្រមស៊ើបអង្កេតលើចំណុចនេះក៏ដោយ នូវចម្លើយតបទៅនឹងពាក្យសុំបំពេញកិច្ចស៊ើបសួរ និងការបំភ្លឺដែលដាក់ដោយមេធាវីការពារក្ដីពាក់ព័ន្ធនឹងការ ប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម (បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១១០-១១២) និង (២) ការយោងដោយសហចៅក្រមស៊ើបអង្កេតទៅលើចម្លើយសារភាពដែលបានមកដោយសារការធ្វើទារុណកម្ម ដើម្បីសន្និដ្ឋាននៅកថាខណ្ឌ១១៨៨ នៃដីកាដំណោះស្រាយថា ខៀវ សំផន"បានចូលរួមក្នុងការចាប់ខ្លួនវន វ៉េត នៅថ្ងៃទី0២ ខែវិច្ឆិកា ឆ្នាំ ១៩៧៨ នៅមន្ទីរគណៈអចិន្ត្រៃយ៍"។

[៤៣] សូមមើល រឿងក្ដី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" "សេចក្ដីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២)" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២00៩ ឯកសារ E176 កថាខណ្ឌ៨។

[៤៤] សាលដីកាលើភាពអាចទទួលយកបាន នៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២0១0 ឯកសារ D130/10/12 កថាខណ្ឌ២៥-២៩។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

00637189



របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានការពារ ក្នុងករណីដែលគាត់អាចទទួលបានពីយុត្តិសាស្ត្រនេះ នៅពេលជំនុំជម្រះក្តី។

២៣. ទាក់ទងនឹងផលវិបាកបណ្តាលមកពីអវត្តមាន នៃការឆ្លើយតបពីសំណាក់ម្ចាស់បណ្តឹងឧទ្ធរណ៍ ទៅនឹងដីកាសន្និដ្ឋានស្ថាពរស្តីពីបូរណភាពនៃដំណើរការនីតិវិធីស៊ើបសួរទៅតាមន័យទូលំទូលាយ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជម្រះ)គឺជាការបញ្ចប់ដំណើរការនីតិវិធីស៊ើបសួរ ដូចដែលឈ្មោះដីកានេះបានបញ្ជាក់ស្រាប់។ ដើម្បីវាយតម្លៃលើចរិតយុត្តិធម៌នៃដំណើរការនីតិវិធីមុនពេលការកាត់សេចក្តី កិច្ចស៊ើបសួរផ្សេងៗគ្នាមិនអាចយកមកពិចារណាដាច់តែឯងបានទេ បន្តែត្រូវពិចារណាផ្អែកលើដំណើរការនីតិវិធីទាំងមូលផងដែរ។ ទាំងនៅក្នុងប្រព័ន្ធច្បាប់ ដែលផ្តល់អំណាចលើសលប់ដល់ចៅក្រមក្នុងដំណើរការនីតិវិធី ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង ការពិភាក្សាតទល់អាចធ្វើទៅបាននៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី។ ការណ៍ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញ ដោយម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ មានន័យដោយមិនអាចប្រកែកបានថា ផ្នែកចុងក្រោយនៃដំណើរការនេះមិនមានលក្ខណៈតតាំងគ្នា ចំពោះមុខទាំងស្រុងទេ តែមិនមានន័យថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានធ្វើឡើងដោយឆ្លងកាត់ការពិភាក្សាដេញដោល ដូចដែលដើមបណ្តឹងបានអះអាងទេ។ បណ្តឹងឧទ្ធរណ៍ផ្សេងៗដែលបានធ្វើឡើងដោយភាគីនានា បានអនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះអះអាងថា ភាគីទាំងនេះ រួមទាំងម្ចាស់បណ្តឹងឧទ្ធរណ៍ផងដែរ អាចលើកឡើងពីទស្សនៈរបស់ខ្លួន ដោយដេញដោលចំពោះមុខលើបញ្ហាអង្គហេតុ និងអង្គច្បាប់ នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីស៊ើបសួរ។ ដូច្នេះ កិច្ចស៊ើបសួរពុំត្រូវបានបំពេញដោយអយុត្តិធម៌នោះទេ បើគ្រាន់តែពុំមានចម្លើយតបពីសំណាក់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះ។ ជាចុងក្រោយ នីតិវិធីដែលអនុវត្ត នាដំណាក់កាលនៃការកាត់សេចក្តីដែលនឹងមកដល់ មានលក្ខណៈតតាំងចំពោះមុខពេញលេញ។

២៤. អង្គបុរេជំនុំជម្រះងាកមកផ្អែកលើអំណះអំណាងទីពីរ ដែលដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងដើម្បីស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការបកស្រាយឲ្យបានទូលំទូលាយនូវសិទ្ធិរបស់ម្ចាស់បណ្តឹង ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះសង្កេតឃើញថា ផ្នែកនៃបណ្តឹងឧទ្ធរណ៍ស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ គ្រាន់តែលើកឡើងពីការដែលដើមបណ្តឹងមិនបានទទួល នូវ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

វាល់ឯកសារព័ត៌មានដែលអាចឱ្យខ្លួនត្រៀមរៀបចំការការពារខ្លួនបាន[៤៥] តែមិនបានពន្យល់ពីមូលហេតុដែលការមិនមានវាល់ឯកសារព័ត៌មានទាំងនេះ ទាមទារនូវការធ្វើការបកស្រាយឱ្យបានទូលំទូលាយនូវសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ ក៏ប៉ុន្តែដូចពេលមុនដែរ អង្គបុរេជំនុំជម្រះនឹងពិនិត្យនូវផលប៉ះពាល់នៃទឡ្ហីករណ៍ទាំងនេះ ដែលបានលើកឡើងយ៉ាងស៊ីជម្រៅដោយម្ចាស់បណ្តឹងឧទ្ធរណ៍លើចំនុចនេះ ដែលអង្គបុរេជំនុំជម្រះយល់ឃើញថា មានលក្ខណៈសមស្រប ពាក់ព័ន្ធនឹងភាពដែលអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍។ ម្ចាស់បណ្តឹងឧទ្ធរណ៍ បានលើកសំអាងអំពីការមិនគោរពសិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវសំណៅបកប្រែជាភាសាបារាំង នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយម្ចាស់បណ្តឹងបង្ហាញថា ជើងទំព័រចំនួន៣៣៧ទំព័ររបស់សំណៅបកប្រែជាភាសាបារាំងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ សុទ្ធតែជាភាសាអង់គ្លេសទាំងអស់ ព្រមទាំងឯកសារភស្តុតាងដែលគាំទ្រការចោទប្រកាន់ដូចមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផងដែរ។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានបញ្ជាក់ថា សិទ្ធិនេះត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ ដោយតម្កល់ដីកាទាក់ទងនឹងការបកប្រែឯកសារ[៤៦]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ប្រសិនណាជាអង្គបុរេជំនុំជម្រះមិនបានតម្កល់ដីកានេះជាផ្លូវការក៏ដោយ ក៏អង្គបុរេជំនុំជម្រះបានយោងទៅលើខ្លឹមសាររបស់វាក្នុងការប្រកាសបដិសេធបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះដែរ។ បញ្ញត្តិដែលបង្កើតឡើង ដោយដីកាទាក់ទងនឹងការបកប្រែឯកសារ បានធ្វើការបែងចែករវាងឯកសារ ដែលត្រូវបកប្រែជាភាសាបារាំង ដោយមិនចាំបាច់តម្រូវឱ្យសហមេធាវីធ្វើការស្នើសុំ និងឯកសារផ្សេងៗទៀតនៃសំណុំរឿង ដែលតម្រូវឱ្យសហមេធាវីប្រើប្រាស់ធនធានខាងផ្នែកភាសានៅក្នុងក្រុមរបស់ខ្លួនដើម្បីធ្វើការបកប្រែ[៤៧] និងក្នុងករណីចាំបាច់ ធ្វើការស្រង់យកនូវឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនេះ ដែលខ្លួនចង់ស្នើសុំឱ្យមានការបកប្រែ[៤៨]។ ទោះជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទាំងដីកាទាក់ទងនឹងការបកប្រែ និងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែឯកសារសុទ្ធតែមិនបានសម្រេចអំពីរយៈពេលកំណត់ ដែលត្រូវដាក់សំណៅបកប្រែជាភាសាបារាំង នូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងនូវវាល់ឯកសារភស្តុតាងដែលគាំទ្រការចោទប្រកាន់ ដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

---

[៤៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥៤។

[៤៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៦៩ យោងទៅលើសាលដីកាទាក់ទងនឹងការបកប្រែ។

[៤៧] សាលដីកាទាក់ទងនឹងការបកប្រែ កថាខណ្ឌ៤៦-៤៧។

[៤៨] សាលដីកាទាក់ទងនឹងការបកប្រែ កថាខណ្ឌ៤៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

២៥. ទាក់ទងនឹងបញ្ហានៃការបកប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាបារាំង អង្គបុរេជំនុំជម្រះយល់ឃើញថា ប្រាកដណាស់ ការបកប្រែនេះត្រូវធ្វើចំពោះកំណត់សម្គាល់ជើងទំព័រផងដែរ។ ចំណែករយៈពេលដែលកំណត់សម្រាប់ផ្ដល់សំណៅបកប្រែនេះទៅមេធាវីការពារក្ដី រយៈពេលនេះត្រូវតែអនុញ្ញាតឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍អាចអនុវត្តយ៉ាងមានប្រសិទ្ធភាព នូវសិទ្ធិរបស់ខ្លួនក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍។ ត្រូវកត់សម្គាល់ថា វាមិននៅក្នុងករណីនេះទេ។ ក្នុងការកត់សម្គាល់ដោយកង្វល់ថា សំណៅជាភាសាបារាំងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានកំណត់សម្គាល់ជើងទំព័រចំនួន៥៤១៩ សុទ្ធតែជាភាសាអង់គ្លេស អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យផ្នែកបកប្រែភាសាធ្វើការបកប្រែកំណត់សម្គាល់ជើងទំព័រទាំងនោះ ជាភាសាបារាំង និងប្រគល់ជូនសហមេធាវីម្ចាស់បណ្ដឹងឧទ្ធរណ៍ មិនឱ្យហួសថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ និងផ្ដល់រយៈពេល១៥ថ្ងៃ ដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្នុងការដាក់រាល់ទឡ្ហីករណ៍បន្ថែម ដូចដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងវិធាន៧៥(៣)(ក)នៃវិធានផ្ទៃក្នុង ដែលម្ចាស់បណ្ដឹងឧទ្ធរណ៍មានបំណងលើកឡើងជាយថាហេតុនៅក្នុងបណ្ដឹងឧទ្ធរណ៍នោះ[៤៩]។ ក្នុងរយៈអនុញ្ញាត១៥ថ្ងៃខាងលើនេះ ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនបានដាក់ទឡ្ហីករណ៍បន្ថែមអ្វីឡើយ។ ជាមួយគ្នានេះដែរ នាដំណាក់កាលនេះ អង្គបុរេជំនុំជម្រះមិនជឿជាក់ថា កាលៈទេសៈនេះ តម្រូវឱ្យធ្វើការពង្រីកនូវសិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ហួសពីវិធានការដែលបានបង្ហាញខាងលើ ក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រៅអំពីបញ្ហានានាដែលពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។

២៦.ទាក់ទងនឹងឯកសារភស្ដុតាងដែលយោងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ប្រសិនណាជាអត្ថបទនៃដីកាដកស្រង់ឬជួនកាលការបកស្រាយក្នុងអត្ថន័យដូចគ្នា នូវឯកសារភស្ដុតាងទាំងនេះក៏ដោយ ក៏ដីកានេះជាញឹកញាប់តែងតែយោងទៅលើឯកសារទាំងមូលឬផ្នែកខ្លះៗនៃអត្ថបទ ដោយមានការបញ្ជាក់ជាកំណត់សម្គាល់ជើងទំព័រដែរ។ ប្រសើរបំផុតនោះ គឺសំណៅបកប្រែជាភាសាបារាំងនូវរាល់ឯកសារទាំងមូល ឬផ្នែកខ្លះនៃឯកសារ ដែលដីកាយោងទៅលើ គួរតែមានក្នុងពេលជាមួយគ្នានឹងសំណៅដើមនៃដីកាដែរ។ ទំហំនៃសំណុំរឿងមិនអនុញ្ញាតិឱ្យធ្វើដូច្នេះបាននោះទេ ហើយម្យ៉ាងទៀត អង្គបុរេជំនុំជម្រះយល់ឃើញថា ដោយហេតុផលយុត្តាធិការរបស់អង្គបុរេជំនុំជម្រះមានកំណត់ការទាមទារធ្វើរបៀបនេះគឺមិនអាចទៅរួចឡើយ។ បណ្ដឹងឧទ្ធរណ៍មិនពន្យល់ ថាតើការណ៍ដែលបណ្ដឹងមិន

[៤៩] ដីកាបង្គាប់ដល់អង្គភាពបកប្រែទាក់ទងនឹងការបកប្រែជើងទំព័រនៃដីកាដំណោះស្រាយជាភាសាបារាំងនិងការណែនាំដល់មេធាវីការពារក្ដី ខៀវ សំផន ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ ("ដីកាបង្គាប់របស់ អបជ")។

លើកឡើងថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាការភ័ន្តច្រឡំដែលជាលទ្ធផលនៃជម្រើស ឬក៏ជាផលវិបាកនៃការអវត្តមានក្នុងការបកប្រែជាភាសាបារាំងនូវកំណត់សម្គាល់ជើងទំព័រ និងឯកសារទាំងឡាយ ឬផ្នែកខ្លះនៃឯកសារដែលបានយោងទៅលើផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះពាក់ព័ន្ធនឹងយុត្តាធិការនោះទេ..

២៧. អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេច ដោយបដិសេធនូវទឡ្ហីករណ៍ ដែលលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ដែលតាមរយៈទឡ្ហីករណ៍ទាំងនោះ សមធម៌តម្រូវឱ្យអង្គបុរេជំនុំជម្រះពង្រីកដែនយុត្តាធិការរបស់ខ្លួន ដោយមូលហេតុគ្មានការបកប្រែជាភាសាបារាំងនូវកំណត់សម្គាល់ជើងទំព័រ នៃដីកាដំណោះស្រាយ និងឯកសារភស្តុតាងដែលជាមូលដ្ឋាននៃដីកានេះ។ អង្គបុរេជំនុំជម្រះក៏បានបដិសេធចោលផងដែរនូវភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ដោយឈរលើវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះយល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញទឡ្ហីករណ៍ណាមួយផ្សេងទៀត ទាក់ទងនឹងភាពអាចទទួលយកបាន នូវផ្នែកទីបីនៃអំណះអំណាងបណ្តឹងឧទ្ធរណ៍ទីមួយរបស់ខ្លួន ដូចជាភាពពុំច្បាស់លាស់នៃកិច្ចដំណើរការរបស់សហចៅក្រមស៊ើបអង្កេត និងនូវផ្នែកទាំងមូល នៃអំណះអំណាងបណ្តឹងឧទ្ធរណ៍ទីពីររបស់ខ្លួនដែលលើកឡើងអំពីលក្ខណៈមិនពេញលេញ ដាក់បន្ទុកនិងគ្រោះថ្នាក់នៃកិច្ចស៊ើបសួរ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះជាយ៉ាងណាក៏ដោយ អំណះអំណាងទាំងនេះមានគោលដៅទទួលបាននូវលទ្ធផលដូចគ្នានឹងបណ្តឹងឧបត្បត្តិហេតុ ដែលមានគោលដៅផ្អាកភ្លាមៗនិងជាស្ថាពរ នូវនីតិវិធីប្រឆាំងនឹងលោក ខៀវ សំផន ដោយមូលហេតុមានការរំលោភលើនីតិវិធី ពោលគឺសំដៅទទួលបាន នូវការលុបចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ម៉្យាងទៀត សំណើសុំនេះបានលើកឡើងផងដែរថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានរំលោភជាក់ស្តែងលើវិធាននៃកិច្ចស៊ើបសួរ ហើយថា ដីកានេះធ្វើឡើងដើម្បីដាក់បន្ទុក[៥០]។

## III. ការរក្សាការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទ

២៨. អនុលោមតាមអនុវិធាន៦៨(២) នៅពេលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនថាលក្ខណៈនៃបណ្តឹងឧទ្ធរណ៍នោះយ៉ាងណាទេ "អានុភាពនៃដីកាឃុំខ្លួន ឬដីកាដោះលែងជន

[៥០] បណ្តឹងឧបត្បត្តិហេតុ ដែលមានគោលដៅផ្អាកភ្លាមៗនិងជាស្ថាពរនូវនីតិវិធី ដែលធ្វើឡើងប្រឆាំងនឹងលោក ខៀវ សំផន ដោយមូលហេតុមានការរំលោភលើនីតិវិធី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ១។

ត្រូវចោទឲ្យនៅក្រៅឃុំរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តរហូតដល់មានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ"។

២៩. ជនជាប់ចោទមិនបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ដែលបានចេញនៅក្នុងដីកាដំណោះស្រាយ។ គ្មានកាលៈទេសៈពិសេសណា ក្រៅពីការអះអាងលើការបញ្ជូនរឿងទៅជំនុំជម្រះពីអង្គបុរេជំនុំជម្រះ ដែលធ្វើឲ្យរឹងម៉ាំពីមូលហេតុ ដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនជាប់ចោទនោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយវាក៏ធ្វើឲ្យរឹងម៉ាំផងដែរពីភាពចាំបាច់ ដើម្បីរក្សាខ្លួនគាត់ ក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងដំណើរការនីតិវិធី ការពារសន្តិសុខគាត់ រក្សាសណ្តាប់ធ្នាប់សាធារណៈ និងរាំងកុំឲ្យជនជាប់ចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ បំផ្លាញភស្តុតាង ប្រសិនបើត្រូវបានដោះលែង[៥១]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា មូលហេតុដែលផ្តល់ឲ្យដោយសហចៅក្រមស៊ើបអង្កេត ដើម្បីបង្គាប់ថា ជនជាប់ចោទនៅតែរក្សាការឃុំខ្លួនបណ្តោះអាសន្ន ដែលអង្គបុរេជំនុំជម្រះយកតាម មានយុត្តិកម្មថា អង្គបុរេជំនុំជម្រះបង្គាប់ថា ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន យោងតាមវិធាន៦៨(៣)នៃវិធានផ្ទៃក្នុង ត្រូវបានបង្គាប់ឲ្យបន្តថិរវេលា រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

ភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១១

អង្គបុរេជំនុំជម្រះ

ប្រធាន

| | | | | |
|---|---|---|---|---|
| Rowan DOWNING | ន៉ី ថុល | Catherine MARCHI-UHEL | ហួត វុទ្ធី | ប្រាក់ គឹមសាន |

---

[៥១] វិធានផ្ទៃក្នុង ៦៣(៣)(ក)និង(ខ) ១ ដល់ ៥។